ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...៣៧១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ពីការកែសម្រួលអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

អានឡាម ឯកសាររដ្ឋបាលសាធារណៈ - https://t.me/oa_channel

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការបង្កើតមូលនិធិហិរញ្ញប្បទានគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម។

## សម្រេច

**មាត្រាមួយ .-**

មាត្រា៥ និងមាត្រា១៥ នៃអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបានកែសម្រួល ដូចខាងក្រោម៖

### ជំពូកទី២
### ប្រាក់ឧបត្ថម្ភ និងលក្ខខណ្ឌនៃការទទួលផល

**មាត្រា៥ ថ្មី .-**

គ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបណ្ណសមធម៌ ត្រូវទទួលបានប្រាក់ឧបត្ថម្ភ ដូចខាងក្រោម៖

**១. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទីប្រជុំជនក្នុងរាជធានីភ្នំពេញ**

| ល.រ | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានបណ្ណសមធម៌ (ប្រភេទ ១ និងប្រភេទ ២) | ១២០ ០០០ រៀល | ១២០ ០០០ រៀល |
| ២ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៣ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៤ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៥ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |

២. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទីប្រជុំជនក្រៅពីរាជធានីភ្នំពេញ

| ល.រ | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ (ប្រភេទ ១ និងប្រភេទ ២) | ១២០ ០០០ រៀល | ១២០ ០០០ រៀល |
| ២ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៣ | ជនមានពិការភាពក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៤ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |
| ៥ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ៤០ ០០០ រៀល | ២៨ ០០០ រៀល |

៣. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅជនបទ

| ល.រ | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ (ប្រភេទ ១ និងប្រភេទ ២) | ៨០ ០០០ រៀល | ៨០ ០០០ រៀល |
| ២ | កុមារអាយុពី ០-៥ឆ្នាំក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៣ | ជនមានពិការភាពក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៤ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៥ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |

## ជំពូកទី៩
## រយៈពេលនៃការអនុវត្ត

**មាត្រា១៥ ថ្មី .-**

កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ត្រូវបន្តអនុវត្តរហូតដល់ខែមីនា ឆ្នាំ២០២៤។ ចំពោះទំហំប្រាក់ឧបត្ថម្ភ ដូចមានចែងក្នុង **មាត្រា ៥ថ្មី** ត្រូវអនុវត្តចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២៤។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីគ្រប់ក្រសួង អគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១១រោច ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែ ធ្នូ ឆ្នាំ២០២៣ ✓

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ**សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ